**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 25-Apr-2012, 14:53
CMS/CFO: Kauv Keoratanak

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១៤)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (14)

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ឹម ប្រធាន**
**ចៅក្រម Motoo Noguchi**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Chandra Nihal Jayasinghe**
**ចៅក្រម យ៉ា ណារិន**

កាលបរិច្ឆេទឯកសារ៖ ២៥ ខែ មេសា ឆ្នាំ ២០១២
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ **សាធារណៈ**

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង*របស់មន្ត្រីច្បាប់ជាន់ខ្ពស់

---

| **ជនជាប់ចោទ៖** | **សហមេធាវីការពារក្តីជនជាប់ចោទ៖** | **សហព្រះរាជអាជ្ញា៖** |
| --- | --- | --- |
| អៀង សារី | អាង ឧត្តម<br>Michael G. KARNAVAS | ជា លាង<br>Andrew CAYLEY |

**មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលបណ្តឹងសាទុក្ខភ្លាមៗ របស់មេធាវីការពារក្តី អៀង សារី ("មេធាវីការពាក្តី") ជំទាស់នឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* រវាងមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ជាមួយនឹងក្រុមមេធាវីការពារក្តីផ្សេងៗ។

## I. **ប្រវត្តិនីតិវិធី**

១ នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សរណៈមួយ បដិសេធចោលសំណើរបស់មេធាវីការពារក្តី[1] ស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់ចម្លងជូនភាគីទាំងអស់ នូវការប្រាស្រ័យទាក់ទងទាំងអស់ដែលទាក់ទងនឹងបញ្ហារៀបចំសវនាការ "សេចក្តីសម្រេចដែលរងការជំទាស់"[2]។

២ នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២ មេធាវីការពារក្តីបានដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចដែលរងការជំទាស់ ជាភាសាអង់គ្លេសតែប៉ុណ្ណោះ "បណ្តឹងសាទុក្ខ"[3]។ ឯកសារបកប្រែជាភាសាខ្មែរ ត្រូវបានជូនដំណឹងនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១២[4] ហេតុដូច្នេះ កាលបរិច្ឆេទ

---

[1] សំណើរបស់លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E154 ("សំណើសុំ")។

[2] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានឈ្មោះថា "សំណើរបស់មេធាវីការពារក្តីជនជាប់ចោទ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ (ឯកសារ E154)" ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E154/1។

[3] បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់លោក អៀង សារី សុំឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហ និងដោយតម្លាភាពជាមួយភាគីទាំងអស់ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២ ឯកសារ E154/1/1/1 ("បណ្តឹងសាទុក្ខ")។

[4] អនុលោមតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ (វិសោធ. ទី៧) អង្គជំនុំជម្រះតុលាការកំពូល បានផ្តល់ការអនុញ្ញាតឲ្យដាក់សំណៅបណ្តឹងសាទុក្ខជាភាសាខ្មែរ "ឲ្យបានឆាប់រហ័សបំផុត"។

កំណត់សម្រាប់ចេញសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល គឺនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២[5]។

៣ នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់សារណាតបរបស់ខ្លួន[6] ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២។

៤ នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ មេធាវីការពារក្តី បានដាក់ការឆ្លើយតបទៅនឹងសារណាតបរបស់ខ្លួន[7]។

## II. សារណាស្តីពីភាពអាចទទួលយកបាន

៥ មេធាវីការពារក្តីលើកឡើងថា បណ្តឹងសាទុក្ខអាចទទួលយកបាន ផ្អែកតាមមូលដ្ឋានចំនួន ៣៖ (i) វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង; (ii) វិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង និង (iii)វិធាន ២១ នៃវិធានផ្ទៃក្នុង។

៦ មេធាវីការពារក្តីលើកឡើងថា បណ្តឹងសាទុក្ខអាចទទួលយកបាន អនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ដោយសារតែអង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយមិនបានចេញ “សេចក្តីសម្រេចដែលមានសំអាងហេតុ” និងបានបង្គាប់ភាគីផ្សេងទៀត មិនឲ្យឆ្លើបតបទៅនឹង

---

[5] វិធាន ១០៨(៤)(ស្ទួន)(ក) និងវិធាន ១០៨(២) នៃវិធានផ្ទៃក្នុង (វិសោធ. ទី៨)។ សេចក្តីសង្ខេបសំអាងហេតុនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ ឯកសារ E116/1/6 ជើងទំព័រលេខ ០៧។

[6] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសំណើរបស់គាត់ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងដោយចំហ និងដោយតម្លាភាពជាមួយភាគីទាំងអស់ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E154/1/1/2 (“សារណាតប”)។

[7] ការឆ្លើយតបរបស់ អៀង សារី ទៅនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសំណើរបស់គាត់ សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនប្រាស្រ័យទាក់ទងដោយចំហ និងដោយតម្លាភាពជាមួយភាគីទាំងអស់ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E154/1/1/3 (“ការឆ្លើយតប”)។

សំណើនេះ[8]។ បន្ថែមពីលើនេះ មេធាវីការពារក្តីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានមានកំហុសអង្គហេតុ ដោយមិនពិចារណាលើការរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលបណ្តាលមកពីការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* និងបានបំពារបំពានឆន្ទានុសិទ្ធិរបស់ខ្លួន តាមរយៈការបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនធ្វើការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង*[9]។

៧ មេធាវីការពារក្តីលើកឡើងថា បណ្តឹងសាទុក្ខក៏អាចទទួលយកបាន អនុលោមតាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង ពីព្រោះបណ្តឹងនេះទាក់ទងនឹងការជ្រៀតជ្រែកកិច្ចការតុលាការផ្អែកតាមវិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង[10]។ មេធាវីការពារក្តីអះអាងថា សេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងជូនដល់មន្ត្រីច្បាប់ជាន់ខ្ពស់ ក្នុងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* គឺជា "ការអនុវត្តមិនសមហេតុផល...ដែលស្រដៀងគ្នា និងដូចគ្នា បើគិតពីកម្រិតធ្ងន់ធ្ងរ" ទៅនឹងឧទាហរណ៍ផ្សេងៗនៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាល ដែលមានចែងយ៉ាងច្បាស់នៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង[11]។ ជាចុងក្រោយ មេធាវីការពារក្តីលើកឡើងថា បណ្តឹងសាទុក្ខអាចទទួលយកបាន ផ្អែកតាមវិធាន ២១ នៃវិធានផ្ទៃក្នុងតែឯងបាន ពីព្រោះថា ប្រសិនបើបណ្តឹងសាទុក្ខមិនអាចទទួលយកបានទេនោះ សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ ត្រូវបានរំលោភបំពាន[12]។

៨ មេធាវីការពារក្តី ស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលសេចក្តីសម្រេចដែលរងការជំទាស់ និងបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងបញ្ឈប់ការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* លើបញ្ហានានានៃការរៀបចំសវនាការ ព្រមទាំងស្នើសុំឲ្យមានសវនាការជាសាធារណៈ

---

[8] បណ្តឹងសាទុក្ខ កថាខណ្ឌ៥។

[9] បណ្តឹងសាទុក្ខ កថាខណ្ឌ៦-៧។

[10] បណ្តឹងសាទុក្ខ កថាខណ្ឌ៨-១០។

[11] បណ្តឹងសាទុក្ខ កថាខណ្ឌ៩។

[12] បណ្តឹងសាទុក្ខ កថាខណ្ឌ១១។

អនុលោមតាមវិធាន ១០៩(១) នៃវិធានផ្ទៃក្នុង ដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ[13]។

៩ សហព្រះរាជអាជ្ញាឆ្លើយតបថា បណ្តឹងសាទុក្ខគួរតែចាត់ទុកថាមិនអាចទទួលយកបាន ផ្អែកតាមមូលដ្ឋានចំនួនបីដែលបានលើកឡើងដោយមេធាវីការពារក្តី។ ទីមួយ វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង គឺជាបទប្បញ្ញត្តិទូទៅមួយដែលចែងអំពីមូលដ្ឋាននានា ដែលអង្គជំនុំជម្រះត្រូវយកទៅពិចារណាសម្រេចលើគ្រប់បណ្តឹងសាទុក្ខទាំងអស់ ហើយវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង គឺជាបទប្បញ្ញត្តិជាក់លាក់មួយដែលកំណត់អំពីប្រភេទនៃសេចក្តីសម្រេចចំនួនបួន ដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗ[14]។ ទីពីរ ដោយសារតែសំណើសុំដើមរបស់មេធាវីការពារក្តី មិនបានស្នើសុំឱ្យមានការស៊ើបសួរណាមួយអនុលោមតាមវិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង ឬម្យ៉ាងទៀតក៏មិនបានលើកឡើងថា ការអនុវត្តនេះ គឺជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ ដូច្នេះករណីនេះ មិនអាចប្តឹងសាទុក្ខ អនុលោមតាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុងនោះទេ[15]។ បន្ថែមពីលើនេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងខ្លួនឯង មិនអាចជាការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដោយបានដឹង និងដោយចេតនាទេ[16]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាលើកឡើងថា វិធាន ២១ នៃវិធានផ្ទៃក្នុង គឺជា"បទប្បញ្ញត្តិទូទៅមួយដែលសម្រាប់យកមកអនុវត្ត ជាសំខាន់ផុតធ្វើជាវិធានមួយសម្រាប់ធ្វើការបកស្រាយ" និងមិនអាចមានអាទិភាពលើពាក្យពេចន៍នៃវិធាន ១០៤(៤) ដែលមានអត្ថន័យច្បាស់លាស់ និងជាក់លាក់នោះទេ[17]។

---

[13] បណ្តឹងសាទុក្ខ ទំព័រ២៣។

[14] សារណាតប កថាខណ្ឌ៤។

[15] សារណាតប កថាខណ្ឌ៧។

[16] សារណាតប កថាខណ្ឌ៨។

[17] សារណាតប កថាខណ្ឌ៩។

១០ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល បញ្ជូនបណ្តឹងសាទុក្ខទៅផ្នែកគាំពារការការពារក្តីដើម្បីធ្វើការវាយតម្លៃថាតើបណ្តឹងសាទុក្ខនេះ មានលក្ខណៈចាំបាច់ និងសមហេតុផលដែរឬយ៉ាងណា។

១១ នៅក្នុងការឆ្លើយតបរបស់ខ្លួន មេធាវីការពារក្តីនៅតែស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលគួរតែយល់ឃើញថា បណ្តឹងសាទុក្ខអាចទទួលយកបាន និងសម្រេចតាមសំណើដែលបានលើកឡើងក្នុងការឆ្លើយតបនេះ។

## III. ការពិភាក្សា

### ក. ភាពអាចទទួលយកបាន

#### *ក.១. វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង*

១២ យុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការពិចារណាលើបណ្តឹងសាទុក្ខនានា មានចែងនៅក្នុងវិធាន ១០៤ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញពីមុនថា យុត្តាធិការរបស់ខ្លួនក្នុងការពិចារណាបណ្តឹងសាទុក្ខភ្លាមៗ "ត្រូវបានកម្រិតបន្ថែមទៀត"[18] ដោយវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង ហេតុដូច្នេះសេចក្តីសម្រេចនានា ដែលឋិតនៅក្រៅវិសាលភាពនៃវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង អាចប្តឹងសាទុក្ខបាន បន្ទាប់ពីចេញសាលក្រមចុងក្រោយសិន[19]។ សេចក្តីសម្រេចផ្សេងទៀត បានបដិសេធចោលប្រហាក់ប្រហែលគ្នានេះដែរនូវបណ្តឹងសាទុក្ខដែលមិនអាចទទួលយកបាន ពីព្រោះបណ្តឹងសាទុក្ខទាំងនោះមិនស្ថិតនៅក្នុងវិសាលភាពនៃវិធាន ១០៤(៤) នៃ

---

[18] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខដែលបានដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ និងក្រុម៣ ប្រឆាំងនឹងសេចក្តីសម្រេចធ្វើឡើងដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ E169/1/2 កថាខណ្ឌ១០។

[19] វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

វិធានផ្ទៃក្នុង[20]។ ហេតុដូច្នេះ ទឡ្ហីករណ៍របស់មេធាវីការពារក្ដីទាក់ទិននឹងភាពអាចទទួលយកបានផ្អែកតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ត្រូវបានបដិសេធចោល។

### *ក.២. វិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង*

១៣ វិធាន ១០៤(៤)(ឃ) ចែងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹង "សេចក្ដីសម្រេច*ស្ដីពី* វិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង។ ទោះបីជាវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង មិនតម្រូវថា សេចក្ដីសម្រេចមួយ "យោងខ្លួនឯង" ថាជា "សេចក្ដីសម្រេចស្ដីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ"[21] ក៏សំណើសុំនេះ មិនគួរ "បង្ហាញអំពីការលើកឡើងនានា ដែលជាក់ស្ដែងមិនអាចទទួលយកបានតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងនោះទេ"[22]។ បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងសាជាថ្មីថា "ការសម្រេចរបស់តុលាការដែលមានកំហុស គឺមិនគ្រប់គ្រាន់តាមផ្លូវច្បាប់ដើម្បីបំពេញនូវបទដ្ឋានស្របតាមវិធាន ៣៥ ឡើយ"[23]។ មេធាវីការពារក្ដី គ្រាន់តែបានអះអាងនៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួនថា អំពើនោះ បានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ និងពុំមានការលើកឡើងអំពីការជ្រៀតជ្រែកនេះនៅក្នុងសំណើសុំរបស់ខ្លួនទេ។ ប៉ុន្តែ មេធាវីការពារក្ដីបានយោងលើសំណើសុំ និងបណ្ដឹងដែលមិនបានជោគជ័យពីមុនរបស់ខ្លួន ដែលបានលើកឡើងថាការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការ បានកើតមានចំពោះការប្រាស្រ័យទាក់ទងការងារជាមួយ

---

[20] *សូមមើល ឧទា.* សេចក្ដីសម្រេចស្ដីពីសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២១ កញ្ញា ឆ្នាំ ២០១១ ឯកសារ E62/3/10/5/1 (បដិសេធចោលបណ្ដឹងសាទុក្ខដោយសារតែបណ្ដឹងនេះ មិនស្ថិតនៅក្នុងវិធាន១០៤(៤)(ក)-(ឃ) ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការលើបណ្ដឹងសាទុក្ខភ្លាមៗ)។ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ ឯកសារ E130/4/3 (បដិសេធចោលបណ្ដឹងសាទុក្ខ ដោយសារតែបណ្ដឹងនេះ មិនស្ថិតនៅក្នុង "យុត្តាធិការដែលមានកម្រិតរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើបណ្ដឹងសាទុក្ខភ្លាមៗ យោងតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងនោះទេ")។

[21] ការឆ្លើយតប កថាខណ្ឌ២។

[22] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីបណ្ដឹងជិតចិត្តលោកស្រីចៅក្រម Silvia Cartwright ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ១២។

[23] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីបណ្ដឹងជិតចិត្តលោកស្រីចៅក្រម Silvia Cartwright ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E137/5/1/3 កថាខណ្ឌ១៣។

*តែភាគីម្ខាង*រវាងចៅក្រម និងភាគីផ្សេងៗ[24]។ សំណើសុំ និងបណ្ដឹងទាំងនេះ មិនមានលក្ខណៈស្រដៀងគ្នាតាមអង្គហេតុទៅនឹងស្ថានភាពបច្ចុប្បន្នទេ ហើយការយោងជាសង្ខេបរបស់មេធាវីការពារក្ដីនៅក្នុងសំណើសុំ និងបណ្ដឹងទាំងនេះ មិនអាចចាត់ទុកជាការលើកឡើងទាក់ទិននឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការនោះទេ។

## *ក.៣. វិធាន ២១ នៃវិធានផ្ទៃក្នុង*

១៤ អង្គបុរេជំនុំជម្រះ បានសម្រេចពីមុនថា វិធាន២១ នៃវិធានផ្ទៃក្នុង តម្រូវឲ្យអង្គជំនុំជម្រះ "បកស្រាយវិធានផ្ទៃក្នុង តាមមធ្យោបាយណាដែលមានន័យថា បណ្ដឹងឧទ្ធរណ៍នេះក៏អាចទទួលយកបានតាមមូលដ្ឋាននៃវិធាន ២១ ផងដែរ"[25]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះបានរៀបរាប់សេចក្ដីសម្រេចនេះជា "ការបកស្រាយដោយសេរីទៅលើសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ដោយផ្អែកទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង" ប៉ុន្តែសេចក្ដីសម្រេចនេះមិនមែនជាវិធានទូទៅដែលមានសមត្ថកិច្ចទៅលើបណ្ដឹងឧទ្ធរណ៍ ដែលពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី[26]។ ប៉ុន្តែ ភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខ ផ្អែកតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ត្រូវបានចាត់ទុកជាករណីលើកលែង ដែលពាក់ព័ន្ធតែក្នុងករណីដែលអង្គហេតុ និងកាលៈទេសៈជាក់លាក់តម្រូវឲ្យមានការបកស្រាយដោយទូលំទូលាយ ទៅលើសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍តែប៉ុណ្ណោះ[27]។ បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា វិធាន២១ នៃវិធានផ្ទៃក្នុង "ត្រូវតែអានក្នុងន័យថា ការបកស្រាយវិធានផ្ទៃក្នុង មិនត្រូវឲ្យមានការរំលោភលើប្រយោជន៍ណាមួយរបស់ជនជាប់ចោទ ដែលកើតចេញពីសិទ្ធិសារវ័ន្ត ដែលត្រូវបានធានានៅក្នុងលក្ខន្តិកៈ និង

---

[24] សំណើសុំ កថាខណ្ឌ ១០។

[25] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំការអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12 កថាខណ្ឌ១៨។

[26] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើស្ដីពីការរក្សាសម្ងាត់ សមភាព និងភាពយុត្តិធម៌ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ A410/2/6 ("សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេត") កថាខណ្ឌ១០។

[27] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេត កថាខណ្ឌ១០។

លិខិតុបករណ៍អន្តរជាតិនានាជាធរមាន”[28] ដែលខុសគ្នាឆ្ងាយពីការធានាជាស្វ័យប្រវត្តិចំពោះជនជាប់ចោទនូវការបកស្រាយវិធានផ្ទៃក្នុង ដែលផ្តល់នូវផលប្រយោជន៍ក្នុងរាល់ករណី។

១៥ នៅក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងសាជាថ្មីថា ពុំមានសិទ្ធិជាទូទៅណាមួយក្នុងការប្តឹងសាទុក្ខបន្ទាន់បង្ខំ ដែលអាចត្រូវបានកំណត់ដោយយុត្តាធិការចង្អៀត ផ្អែកតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងនោះទេ[29]។ ជនជាប់ចោទ បានខកខានក្នុងការបង្ហាញអំពីរបៀបនៃការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង* ដែលនាំឱ្យមានការបដិសេធចោលសិទ្ធិរបស់ខ្លួន ឬបង្ហាញថា ការប្រព្រឹត្តនេះ ឋិតក្នុងករណីលើកលែង ដែលតម្រូវឱ្យអង្គជំនុំជម្រះទទួលយកបណ្តឹងសាទុក្ខនេះ ផ្អែកតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។

១៦ ផ្អែកតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បណ្តឹងសាទុក្ខនេះមិនបានបំពេញលក្ខខណ្ឌតម្រូវនៃភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខភ្លាមៗ ផ្អែកតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងនោះទេ ហេតុដូច្នេះបណ្តឹងសាទុក្ខនេះ មិនអាចទទួលយកបានឡើយ។

### ខ. <u>សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបញ្ជូនបណ្តឹងសាទុក្ខទៅអង្គភាពគាំពារការពារក្តី (“DSS”)</u>

១៧ សហព្រះរាជអាជ្ញាស្នើឱ្យបញ្ជូនបណ្តឹងសាទុក្ខទៅអង្គភាពគាំពារការការពារក្តី ដើម្បីធ្វើការវាយតម្លៃ ថាតើកិច្ចការដែលបានបំពេញមួយនេះ មានទាំងភាពចាំបាច់ និងទាំងភាពសមហេតុផលដែរឬយ៉ាងណា។ មានការអះអាងថា មេធាវីការពារក្តីធ្លាប់បានអនុវត្តដាក់ឯកសារស្តីពីបណ្តឹងសាទុក្ខ

---

[28] សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E50/2/1/4 កថាខណ្ឌ៣៩។

[29] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីអញ្ញត្រកម្មរបស់លោក អៀង សារី តាមវិធាន៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (Ne Bis in Idem)* និងការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E51/15/1/2 កថាខណ្ឌសម្រេចសេចក្តីទី៧ ដែលដកស្រង់*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Norman “សេចក្តីសម្រេចលើពាក្យសុំផ្អាកចិត្តដំណើរការនីតិវិធី និងការបដិសេធសិទ្ធិប្តឹងឧទ្ធរណ៍” (SCSL-2003-08-PT) អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣ កថាខណ្ឌ ១៨-២៥។

ភ្លាមៗ ដែលជាក់ស្តែងមិនអាចឲ្យទទួលយកបាន ដែល"បំពាននីតិវិធីរបស់ អ.វ.ត.ក [និង] មានបន្ទុកធ្ងន់ទៅលើធនធាន និងពេលវេលាដែលមានតិចតួចរបស់អង្គជំនុំជម្រះ"[30]។

១៨ នៅតុលាការ *មិនអចិន្ត្រៃយ៍*នានា វិធានស្តីពីនីតិវិធី និងភស្តុតាង ផ្តល់អំណាចទៅឲ្យអង្គជំនុំជម្រះ ដាក់ទណ្ឌកម្មដល់មេធាវីការពារក្តី ដែលដាក់នូវសំណើដែលត្រូវបានយល់ឃើញថាមានលក្ខណៈ មិនហ្មត់ចត់ ឬរំលោភបំពានលើនីតិវិធី[31]។ អនុលោមតាមបទប្បញ្ញត្តិទាំងនេះ អង្គជំនុំជម្រះធ្លាប់ បានដាក់ទណ្ឌកម្មទៅលើសំណើដែលមានលក្ខណៈមិនហ្មត់ចត់ ដោយបង្គាប់មិនឲ្យប្រធានរដ្ឋបាល ផ្តល់នូវប្រាក់ឈ្នួល និងថ្លៃចំណាយផ្សេងៗទាំងអស់ ឬមួយផ្នែកដែលពាក់ព័ន្ធជាមួយនឹងសំណើ បែបនេះ[32]។ ជាការគួរកត់សម្គាល់នោះ គឺមេធាវីអន្តរជាតិរបស់ អៀង សារី គឺលោក Michael

---

[30] សារណាតប កថាខណ្ឌ ១១។

[31] វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការ ICTY វិធាន ៧៣(ឃ)។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការ ICTR វិធាន ៧៣(ច)។ វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ SCSL វិធាន ៤៦(គ)។ សូមមើលផងដែរ វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃ តុលាការ ICTY និងតុលាការ ICTR វិធាន ៤៦។ ក្រមសីលធម៌វិជ្ជាជីវៈមេធាវី ដែលបង្ហាញវត្តមាននៅចំពោះមុខតុលាការ អន្តរជាតិ មាត្រា ២៥ ("មេធាវីមិនត្រូវដាក់បណ្តឹង ឬធ្វើការការពារក្តីឡើយ លើកលែងតែមានមូលដ្ឋានក្នុងការធ្វើដូច្នេះដែល មានលក្ខណៈហ្មត់ចត់ពេញលក្ខណៈច្បាប់...") ។

[32] សូមមើល ឧទាហរណ៍ រឿងក្តី *Nahimana* និងអ្នកផ្សេងទៀត ទល់នឹង រដ្ឋអាជ្ញា ICTR-99-52-A, "សាលដីកាលើ សំណើរបស់ម្ចាស់បណ្តឹងសាទុក្ខ Jean-Bosco Barayagwiza's ស្នើសុំការអនុញ្ញាតដាក់មូលដ្ឋានបន្ថែមនៃបណ្តឹងសាទុក្ខ កែប្រែសេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខ និងកែតម្រូវសារណាបណ្តឹងសាទុក្ខរបស់គាត់" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៦ កថាខណ្ឌ ៥៦ (បដិសេធពុំផ្តល់នូវប្រាក់ឈ្នួលចំពោះសំណើមួយ "ដែលពុំមាន លើកឡើងនូវទឡ្ហីករណ៍ ណាមួយឡើយ" ទាក់ទិននឹងលក្ខខណ្ឌតម្រូវមួយចំនួន (ដូចខាងលើ កថាខណ្ឌ ១៩) និងចំពោះសំណើ មួយទៀត ដែលការ ទាមទារនានាត្រូវបានអង្គជំនុំជម្រះបដិសេធយ៉ាងដាច់ខាត និងយល់ឃើញថា "មិនអាចទទួលយកបានឡើយ" (ដូចខាងលើ កថាខណ្ឌ ៥១))។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Nyiramasuhuko* និងអ្នកផ្សេងទៀត ICTR-97-21-T & ICTR-98-42-T, "សេចក្តី សម្រេចលើសំណើរបស់ Nyiramasuhuko ស្នើសុំបំបែកកិច្ចដំណើរការនីតិវិធី ការជំនុំជម្រះថ្មី និងផ្អាកកិច្ចដំណើរការនីតិវិធី វិធាន ៨២(ខ) និង ៧២(ឃ) វិធានស្តីពីនីតិវិធី និងភ័ស្តុតាង" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០៦ កថា ខណ្ឌ ៨៤ (បដិសេធពុំផ្តល់ប្រាក់ឈ្នួល ដែលពាក់ព័ន្ធនឹងសំណើមួយដែលត្រូវបានគេយល់ឃើញ ថាមានលក្ខណៈមិនហ្មត់ចត់ ពីព្រោះសំណើនោះមានចេតនាទាំឡើងវិញអំពីបញ្ហាដែលត្រូវបានដោះស្រាយពីមុនរួចហើយ)។ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Brđanin* និងអ្នកផ្សេងទៀត IT-99-36-T, "សេចក្តីសម្រេចលើ "សំណើសុំការអនុញ្ញាតប្តឹងសាទុក្ខ ប្រឆាំងនឹងសេចក្តីសម្រេច បំបែកការជំនុំជម្រះក្តី" និងលើ "សំណើសុំពន្យារចិរវេលាកំណត់ដាក់សារណាគាំទ្រសំណើសុំការ អនុញ្ញាតប្តឹងសាទុក្ខ"" អង្គជំនុំ

Karnavas ធ្លាប់ត្រូវបានអង្គជំនុំជម្រះនៃតុលាការ ICTY ក្រើនរំឭក និងដាក់ទណ្ឌកម្មចំពោះការដាក់សំណើដែលមានលក្ខណៈមិនហ្មត់ចត់[33]។

១៩ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅ អ.វ.ត.ក អង្គភាពគាំពារការពារក្តីតម្រូវឱ្យធ្វើការវាយតម្លៃថាតើ ភារកិច្ចដែលបានស្នើឡើង ឬភារកិច្ចដែលពុំអាចប្រមើលដឹងមុន ដែលមេធាវីបានបំពេញរួចហើយនោះ មានលក្ខណៈ"ចាំបាច់ និងសមហេតុផល" ដែរ ឬយ៉ាងណា សម្រាប់ធ្វើការរៀបចំការការពារក្តី[34]។ នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបាន សម្រេច នៅ ក្នុង

---

ជម្រះសាលាដំបូង ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០២ កថាខណ្ឌ ១០-១៣ (យល់ឃើញថា ញត្តិ និងសំណើពុំមានមូលដ្ឋានច្បាស់លាស់ និងមានលក្ខណៈមិនហ្មត់ចត់ឡើយ ដោយសារតែញត្តិ និងសំណើទាំងនោះ មានចេតនា "បង្កឱ្យមានភាពច្របូកច្របល់នៅក្នុងរឿងក្តីនេះនៅចុងបញ្ចប់"។ ដូច្នេះ ប្រធានរដ្ឋបាលត្រូវបានបង្គាប់មិនឱ្យផ្តល់នូវប្រាក់ឈ្នួល និងថ្លៃចំណាយទាំងនោះឡើយ)។

[33] សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Prlić* និងអ្នកផ្សេងទៀត IT-04-74-T, "សេចក្តីសម្រេចលើសំណើសុំឱ្យពិចារណាឡើងវិញ ឬម្យ៉ាងទៀតស្នើសុំការអនុញ្ញាតប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចចុះថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១០ ដែលយកវិធាន ៧៣ (ឃ) នៃវិធានមកអនុវត្តទៅលើមេធាវីការពារក្តី Prlic" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ៦ និងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Prlić* និងអ្នកផ្សេងទៀត IT-04-74-T, "សេចក្តីសម្រេចលើសំណើសុំពិចារណាឡើងវិញលើសេចក្តីសម្រេច ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០ និងការយកវិធាន ៧៣(ឃ) នៃវិធាន មកអនុវត្តទៅលើមេធាវីការពារក្តីរបស់ Prlić" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១០ ទំព័រ ៤-៥ (យល់ឃើញថា សំណើនោះរំលោភបំពានលើនីតិវិធី ពីព្រោះ "ដោយជំទាស់តវ៉ាទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះជាលក្ខណៈប្រព័ន្ធ និងដោយប្រើប្រាស់ពេលវេលា និងធនធានរបស់ខ្លួនយ៉ាងច្រើន អាកប្បកិរិយារបស់មេធាវីការពារក្តី *Prlić* មានភាពមិនហ្មត់ចត់" ។ សំអាងហេតុនេះ នាំឱ្យមានការផ្តល់នូវប្រាក់ឈ្នួល និងថ្លៃចំណាយនានាដែលពាក់ព័ន្ធនឹងសំណើដែលត្រូវបានបដិសេធដោយប្រធានរដ្ឋបាល)។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Prlić* និងអ្នកផ្សេងទៀត IT-04-74-T, "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី Prlić ស្នើសុំការអនុញ្ញាតប្តឹងសាទុក្ខ" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ២-៣ (ព្រមានមេធាវីការពារក្តីថា ការបន្តដំហួសហេតុរបស់ខ្លួនក្នុងការលើកឡើងនូវបញ្ហាដែលត្រូវបានជជែកតវ៉ាយ៉ាងខ្លាំងក្លារួចហើយនោះ អាចនាំឱ្យមានការដាក់ទណ្ឌកម្ម អនុលោមតាមវិធាន ៧៣(ឃ) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY)។ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Blagojević* និងអ្នកផ្សេងទៀត IT-02-60-T, "សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតឆ្លើយតបទៅនឹងសារណាស្តាពររបស់អយ្យការ" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៤ (ក្រើនរំឭកដល់លោក Karnavas ចំពោះការដាក់សំណើដែលមានលក្ខណៈមិនហ្មត់ចត់ និងចំពោះការចោទប្រកាន់មួយចំនួន ទាក់ទិននឹងវិជ្ជាជីវៈ និងសីលធម៌របស់សមាជិករបស់ក្រុមអយ្យការ)។

[34] បទប្បញ្ញត្តិរដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី មាត្រា ១៣.១ និង ១៤.២។

ករណីជាច្រើនថា ការដាក់ឯកសារក្នុងការការពារក្តីត្រូវបញ្ជូនទៅអង្គភាពគាំពារការការពារក្តី និងបានស្នើឡើងផងដែរថា ប្រាក់កម្រៃសម្រាប់មេធាវីការពារក្តីចំពោះការរៀបចំសំណើសុំមួយ ចំនួន មិនត្រូវបានអនុញ្ញាតផ្តល់ទៅឱ្យមេធាវីទេ[35]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គភាពគាំពារការការពារក្តីមានកាតព្វកិច្ចស្របច្បាប់ក្នុងការសម្រេច ដោយឯករាជ្យទៅលើការ បញ្ជូនរបស់អង្គជំនុំជម្រះ។ ទាក់ទិននឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានបញ្ជាក់ថា អំណាចក្នុងការដាក់ទណ្ឌកម្មទៅលើមេធាវីគួរតែ"ត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន ដោយត្រូវគិតដល់ផលប្រយោជន៍នៃយុត្តិធម៌ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ [...និង] ការពុំមានការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ"[36]។

[35] *សូមមើលឧទាហរណ៍* សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង បន្ទាប់ពីមានការបញ្ចេញឯកសារសម្ងាត់នានាដោយគ្មានការអនុញ្ញាត ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E147/1 ទំព័រ ៤ (ភាសាអង់គ្លេស)។ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ទាក់ទិននឹងការយកអង្គហេតុពីសំណុំរឿងលេខ ០០១ ដែល បានវិនិច្ឆ័យរួចហើយ និងអង្គហេតុនៃការដឹងឮជាទូទៅមកអនុវត្តក្នុងសំណុំរឿងលេខ ០០២ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E69/1 ទំព័រ ៣ (ភាសាអង់គ្លេស)។ សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឱ្យមានសវនាការដេញដោលទៅ លើការបំពេញកិច្ចស៊ើបសួរ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E71/1 ទំព័រ ៣ (ភាសាអង់គ្លេស)។ អនុស្សរណៈ ឆ្លើយតបទៅនឹងសំណើដែលបានដាក់ដោយមេធាវីការពារក្តី អៀង សារី (E53/2) ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ E53/2/1 ទំព័រ ១ កថាខណ្ឌ (គ)។ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ស្នើសុំដាក់សំណើសុំឱ្យមាន "ការបញ្ជាក់ថា គាត់នឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញនូវទឡ្ហីករណ៍ផ្ទាល់មាត់ នៅពេលសវនាការបឋមស្តីអំពីអញ្ញត្រកម្មនីមួយៗរបស់គាត់" ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ E65/1 ទំព័រ ២ កថាខណ្ឌ (គ)។ *សូមមើលផងដែរ* អនុស្សរណៈរបស់មន្ត្រីទទួលបន្ទុក របស់អង្គភាពគាំពារការការពារក្តីផ្ញើទៅសហមេធាវីអៀងសារី (ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១១), ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១១, ឯកសារលេខ E130/4/1.1.2។

[36] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Karemera* និងអ្នកផ្សេងទៀត ICTR-98-44-PT, "សេចក្តីសម្រេចលើសំណើសុំធ្វើមោឃៈភាពការដាក់ទណ្ឌកម្ម វិធាន ៧៣(ច) និង ១២០ នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ៦ (ដកស្រង់ពីរឿងក្តី *Karemera* និងអ្នកផ្សេងទៀត ទល់នឹងរដ្ឋអាជ្ញា ICTR-98-44-AR73.4, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ទាក់ទិននឹងការចូលរួមរបស់ចៅក្រមទទួលបន្ទុកករណីពិសេស (*Ad Litem* Judges)", អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ទំព័រ ៤ បានដកស្រង់ដោយមិនត្រឹមត្រូវពីរឿងក្តី *Karemera* និងអ្នកផ្សេងទៀត សាលដីកាលើបណ្តឹងសាទុក្ខរបស់មេធាវីពីសេចក្តីសម្រេចស្របតាមវិធាន ៧៣(ច) (AC) ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៤)។

*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់*

២០ សហព្រះរាជអាជ្ញាអះអាងថា បណ្តឹងសាទុក្ខបច្ចុប្បន្នមួយនេះគឺដូចគ្នាទៅនឹង "ការអនុវត្តដាក់ឯកសារស្តីពីបណ្តឹងសាទុក្ខភ្លាមៗដែលជាក់ស្តែងមិនអាចឲ្យទទួលយកបាន"[37] ដែលត្រូវបានអះអាងថា ធ្វើឡើងដោយមេធាវីការពារក្តី អៀង សារី។ ទោះបីជាយ៉ាងណាក៏ដោយ ជាភស្តុតាងនៃការអនុវត្តបែបនេះ ចម្លើយតបចង្អុលបង្ហាញអំពីបណ្តឹងសាទុក្ខភ្លាមៗមិនលើសពីមួយឡើយ ដែលក្នុងករណីនោះ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធយ៉ាងច្បាស់លាស់នូវសំណើស្រដៀងគ្នាមួយរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំឲ្យបញ្ជូនបណ្តឹងសាទុក្ខទៅអង្គភាពគាំពារការពារក្តី ដើម្បីធ្វើការវាយតម្លៃអំពីភាពចាំបាច់ និងភាពសមហេតុផលរបស់សំណើនោះ[38]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការយល់ឃើញថាបណ្តឹងសាទុក្ខមួយមិនអាចទទួលយកបាន គឺមិនដូចគ្នាទៅនឹងការយល់ឃើញថា បណ្តឹងសាទុក្ខនេះមានលក្ខណៈមិនហ្មត់ចត់ មិនសមហេតុផល ឬមិនចាំបាច់នោះឡើយ ដោយពិចារណាអំពីសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ បណ្តឹងសាទុក្ខបច្ចុប្បន្នមួយនេះពុំមានចេតនាបង្កឲ្យមានការពន្យារពេលវេលា នៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ ឬក៏អាចបង្កឲ្យមានការពន្យារពេលនោះដែរ[39]។ លើសពីនេះទៀត បណ្តឹងសាទុក្ខនេះពុំមានចេតនាតវ៉ាឡើងវិញអំពីបញ្ហា ដែលត្រូវបានដោះស្រាយរួចហើយ ឬរំលោភបំពាននីតិវិធីរបស់ អ.វ.ត.ក ឡើយ ហើយបណ្តឹងសាទុក្ខនេះ ក៏មិនបានផ្អែកលើការយល់ច្រឡំយ៉ាងច្បាស់ក្រឡែត អំពីច្បាប់ជាធរមាននោះឡើយ។ ហេតុដូច្នេះ សំណើរបស់សហព្រះរាជអាជ្ញាត្រូវបានបដិសេធចោល។

---

[37] សារណាតប កថាខណ្ឌ ១១។

[38] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E130/4/3 (បដិសេធយ៉ាងច្បាស់នូវសំណើរបស់សហព្រះរាជអាជ្ញា ដែលបានស្នើសុំនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឲ្យជនជាប់ចោទត្រូវមានវត្តមានដើម្បីស្តាប់ការចោទប្រកាន់ និងសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E130/4/2 កថាខណ្ឌ ១១-១២)។

[39] វិធានផ្ទៃក្នុង ១០៤(៤) ("លើកលែងតែមានចែងក្នុងវិធានផ្ទៃក្នុង ឬការសម្រេចផ្សេងដោយអង្គជំនុំជម្រះសាលាដំបូងបណ្តឹងសាទុក្ខភ្លាមៗមិនមានអានុភាពបង្អង់នីតិវិធីមុខអង្គជំនុំជម្រះសាលាដំបូងទេ")។

00802549



## IV. **ផ្នែកសម្រេចសេចក្តី**

យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ **អង្គជំនុំជម្រះតុលាការកំពូលៈ**

**ប្រកាសបដិសេធ** បណ្តឹងសាទុក្ខចោលជាអាសាបង់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**